20e SOMMET DE
LA FRANCOPHONIE
PHNOM PENH 2026

កម្ពុជាសម្ពោធបើក «ភូមិហ្វ្រង់កូហ្វូនី» ជាផ្លូវការ ដោយអបអរសាទរសន្តិភាព និងភាពចម្រុះនៃវប្បធម៌ ក្នុងកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី លើកទី២០

រាជធានីភ្នំពេញ កម្ពុជា – ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៦ – ថ្ងៃនេះ ព្រះរាជាណាចក្រកម្ពុជា បានសម្ពោធបើកឱ្យដំណើរការជាផ្លូវការនូវ «ភូមិហ្វ្រង់កូហ្វូនី» នៅសួនច្បារវត្តបទុមវតី ដែលជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ និងជាព្រឹត្តិការណ៍អមដ៏សំខាន់នៃកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០។ ពិធីសម្ពោធបើកដ៏អធិកអធមនេះ ប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** ព្រមជាមួយវត្តមានរបស់ **លោកជំទាវ** Louise Mushikiwabo អគ្គលេខាធិការនៃអង្គការអន្តរជាតិហ្វ្រង់កូហ្វូនី (OIF)។

នៅក្នុងសុន្ទរកថាបើក **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ពីសារៈសំខាន់ជាប្រវត្តិសាស្ត្រនៃព្រឹត្តិការណ៍នេះ ដោយមានប្រសាសន៍ថា នេះជាលើកទីមួយហើយដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលនេះ ហើយក៏ជាការវិលត្រឡប់មកកាន់តំបន់អាស៊ីអាគ្នេយ៍ជាលើកដំបូង បន្ទាប់ពីកិច្ចប្រជុំនៅទីក្រុងហាណូយក្នុងឆ្នាំ១៩៩៧។ ឆ្លុះបញ្ចាំងពីមូលបទគោលរបស់កិច្ចប្រជុំកំពូលស្តីពី **«ការបន្តកសាងសន្តិភាព ដើម្បីវិបុលភាពរួម និងស្ថិរភាពយូរអង្វែង»** **សម្តេចធិបតី** បានរំលេចពីមូលបទរបស់ភូមិហ្វ្រង់កូហ្វូនីគឺ៖**«ស្នាមញញឹមខ្មែរ ស្នាមញញឹមហ្វ្រង់កូហ្វូនី»**។ **សម្តេចធិបតី** មានប្រសាសន៍បញ្ជាក់ថា ៖ **«នៅកម្ពុជា ស្នាមញញឹមមិនមែនត្រឹមតែជាការស្វាគមន៍នោះទេ។ ស្នាមញញឹមតំណាងឱ្យភាពកក់ក្តៅ និងសន្តិភាព។»**

លោកជំទាវ Louise Mushikiwabo បានសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា សម្រាប់ការបដិសណ្ឋារកិច្ចដ៏កក់ក្តៅ និងការរៀបចំយ៉ាងល្អឥតខ្ចោះ។ **លោកជំទាវ** បានអបអរសាទរចំពោះការផ្លាស់ប្តូរវប្បធម៌ដ៏សម្បូរបែប ដែលបានស្តែងចេញនៅក្នុងពិធីបើក ជាពិសេសការជួបគ្នារវាងវប្បធម៌កម្ពុជា និងរ៉ាន់ដា នៅលើឆាកតែមួយ។ **លោកជំទាវ** បានគូសបញ្ជាក់ថាទោះបីជាមានចម្ងាយភូមិសាស្ត្រឆ្ងាយពីគ្នាក៏ដោយ ប្រជាជាតិទាំងពីរពិតជាមានភាពធន់ (resilience) ដ៏គួរឱ្យស្ញប់ស្ញែង និងមានបំណងប្រាថ្នារួមគ្នាក្នុងការកសាងអនាគតមួយប្រកបដោយសន្តិភាព និងវិបុលភាព។

លោកជំទាវកិត្តិបណ្ឌិត អ៊ឹង កន្ថាផារី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងជាប្រធានអនុគណៈកម្មការទី៥ បានធ្វើបទបង្ហាញអំពី «ភូមិហ្វ្រង់កូហ្វូនី» ថាជាទីកន្លែងដ៏រស់រវើកសម្រាប់ការស្វែងយល់ការផ្លាស់ប្តូរវប្បធម៌ និងកិច្ចសហប្រតិបត្តិការ ដោយផ្តោតយ៉ាងខ្លាំងទៅលើបរិយាបន្នសម្រាប់មនុស្សគ្រប់រូបជាពិសេសស្ត្រី និងយុវជន។ លាតសន្ធឹងលើផ្ទៃដីប្រមាណ ១០.០០០ ម៉ែត្រការ៉េ ភូមិនេះទទួលស្វាគមន៍ភ្ញៀវទេសចរណ៍តាមរយៈខ្លោងទ្វារដ៏ធំសម្បឹម ដែលចម្លងចេញពីរចនាបថខ្លោងទ្វារទន្លេអ៊ុំនៃរាជធានីអង្គរធំ តំណាងឱ្យមេត្តាករុណា និងសន្តិភាពផ្លូវចិត្ត អមដោយរូបព្រាបសតំណាងឱ្យភាពសុខដុមរមនា។

នៅក្នុងភូមិមានរៀបចំ ពន្លាជាតិចំនួន ៧៣ តំណាងឱ្យប្រទេស និងដៃគូហ្វ្រង់កូហ្វូនី, ស្តង់ពិព័រណ៌ចំនួន ១៣០ បង្ហាញពីគំនិតផ្តួចផ្តើមរបស់ស្ថាប័ននិងធុរកិច្ច, និងភូមិម្ហូបអាហារចំនួន ៣០ ស្តង់ ដែលផ្តល់ជូននូវរសជាតិអាហារចម្រុះមកពីជុំវិញពិភពហ្វ្រង់កូហ្វូនី។ ក្នុងរយៈពេល ៥ ថ្ងៃ ទីតាំងនេះក៏នឹងធ្វើជាម្ចាស់ផ្ទះរៀបចំសន្និសីទ និងកិច្ចពិភាក្សាតុមូលចំនួន ៣០ កម្មវិធី ព្រមទាំងការសម្តែងសិល្បៈនិង វប្បធម៌ចំនួន ៥០ កម្មវិធីផងដែរ។

«ភូមិហ្វ្រង់កូហ្វូនី» នឹងបើកទ្វារស្វាគមន៍សាធារណជនឱ្យចូលទស្សនាដោយសេរី ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៦។ ព្រឹត្តិការណ៍នេះត្រូវបានរំពឹងថានឹងទទួលស្វាគមន៍ភ្ញៀវជាតិ និងអន្តរជាតិប្រមាណ ១០០.០០០ នាក់ ដែលនឹងរួមចំណែកក្នុងការជំរុញភាពជាដៃគូថ្មីៗ ចំណងមិត្តភាព និងការពង្រឹងសាមគ្គីភាពនៃសហគមន៍ហ្វ្រង់កូហ្វូនី។

ព័ត៌មានទំនាក់ទំនងសម្រាប់សារព័ត៌មាន៖

អនុគណៈកម្មការទី៥ – កិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី លើកទី២០

ក្រសួងកិច្ចការនារី ព្រះរាជាណាចក្រកម្ពុជា

cabinet@mowa.gov.kh

(855) 12 658 678

រៀបចំដោយ | Organisé par

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

ORGANISATION INTERNATIONALE DE la francophonie

សហការឧបត្ថម្ភដោយ | Co-sponsorisé par